**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន

**រដ្ឋបាលរាជធានីភ្នំពេញ** សូមប្រកាសជម្រាបជូនដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន លោកគ្រូ-អ្នកគ្រូ បុគ្គលិកអប់រំ មាតាបិតា-អាណាព្យាបាល សិស្សានុសិស្ស និងសាធារណជនទាំងអស់ ឱ្យបានជ្រាបថា ផ្អែកតាមសេចក្តីជូនដំណឹងលេខ ០៧៣/២១ សជណ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ **គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន សម្រាប់កម្រិតអនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវបានអនុញ្ញាតឱ្យដំណើរការឡើងវិញ ចាប់ពីថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ នេះតទៅ** និងក្រោយពេលដែលគ្រឹះស្ថានសិក្សានីមួយៗបានត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) របស់ក្រសួងអប់រំ យុវជន និងកីឡា និងការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។

**គិតត្រឹមរសៀលថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ នេះ រដ្ឋបាលរាជធានីភ្នំពេញ** ដែលមានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញជាសេនាធិការ បានសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលខណ្ឌទាំង១៤ មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ និងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ សម្រេចបានកិច្ចការសំខាន់ៗ ក្នុងការត្រៀមលក្ខណៈសម្បត្តិសម្រាប់ការបើកដំណើរការឡើងវិញនូវគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន សម្រាប់កម្រិតអនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដូចខាងក្រោម៖

- អត្រាភាគរយខ្ពស់នៃការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ គ្រប់ដូស ជូនដល់លោកគ្រូ-អ្នកគ្រូ និងបុគ្គលិកអប់រំ សរុបបាន **១០.៩៤៨ នាក់** ស្មើនឹង **៩៨%** នៃស្ថិតិសរុប រីឯចំនួន **២%** ដែលនៅសេសសល់ ភាគច្រើនមានបញ្ហាសុខភាពផ្ទាល់ខ្លួន និងកំពុងបន្តផ្តល់ជូនវ៉ាក់សាំងដូសទី៣ ឬ ដូសជំរុញ បន្ថែមទៀត
- អត្រាភាគរយខ្ពស់នៃការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ គ្រប់ដូស ជូនដល់កុមារ និងយុវវ័យមានអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ សរុបបាន **១៩៩.៦០៣ នាក់** លើសពីផែនការដែលបានកំណត់
- គ្រឹះស្ថានសិក្សាកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ នៅរាជធានីភ្នំពេញ ដែលត្រូវបើកដំណើរការឡើងវិញមានចំនួនសរុប **២២៧ ទីតាំង** (គ្រឹះស្ថានសាធារណៈ ៦៨ ទីតាំង និងគ្រឹះស្ថានឯកជនចំនួន ១៥៩ ទីតាំង) មានលោកគ្រូ-អ្នកគ្រូ និងបុគ្គលិកអប់រំបម្រើការងារចំនួន **១០.៤៤៣ នាក់** និងមានសិស្សានុសិស្សត្រូវចូលរៀនវិញចំនួន **១៣៩.៥៧៨ នាក់**
- យុទ្ធនាការបាញ់ថ្នាំសម្លាប់មេរោគរៀបចំដោយរដ្ឋបាលរាជធានីភ្នំពេញ និងដោយមានការចូលរួមពីបញ្ជាការដ្ឋានកងពលតូចលេខ ៧០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឃួង ស្រេង អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** កាលពីព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ បានចាត់ចែងបាញ់ថ្នាំសម្លាប់មេរោគនៅតាមគ្រឹះស្ថានសិក្សាសាធារណៈចំនួន **៦៨ ទីតាំង** រួចរាល់ជាស្ថាពរ។ ដោយឡែក គ្រឹះស្ថានសិក្សាឯកជនចំនួន **១៥៩ ទីតាំង** ផ្សេងទៀត បានម្ចាស់ការចាត់ចែងបាញ់ថ្នាំសម្លាប់មេរោគដោយខ្លួនឯងរួចរាល់ផងដែរ ក្រោមការត្រួតពិនិត្យរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់



៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៥ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- យុទ្ធនាការប្រើប្រាស់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Covid-19 Rapid Antigen Test) មុនពេលបើកដំណើរការសាលារៀននីមួយៗឡើងវិញ ដើម្បីធ្វើតេស្តរហ័សចំពោះលោកគ្រូ-អ្នកគ្រូ និងបុគ្គលិកអប់រំចំនួន **១០.៤៤៣ នាក់** ក្នុងនោះ លោកគ្រូ-អ្នកគ្រូ និងបុគ្គលិកអប់រំចំនួន **១០.៤១៩ នាក់** ស្មើនឹង **៩៩,៧៧%** ទទួលបានលទ្ធផលតេស្តអវិជ្ជមានជំងឺកូវីដ-១៩ និងលោកគ្រូ-អ្នកគ្រូ និងបុគ្គលិកអប់រំចំនួនត្រឹមតែ **២៤ នាក់** ស្មើនឹង **០,២៣%** ប៉ុណ្ណោះ ទទួលបានលទ្ធផលតេស្តវិជ្ជមានជំងឺកូវីដ-១៩ ។ ក្នុងចំណោមលោកគ្រូ-អ្នកគ្រូ និងបុគ្គលិកអប់រំ ដែលបានរកឃើញវិជ្ជមានជំងឺកូវីដ-១៩ គឺមានស្ថានភាពសុខភាពធម្មតា និងមិនមានរោគសញ្ញាធ្ងន់ធ្ងរឡើយ ដោយសារពួកគាត់បានទទួលវ៉ាក់សាំងចំនួន ២ ដូស និងខ្លះទៀតបានទទួលវ៉ាក់សាំងដូសទី៣ ឬ ដូសជំរុញរួចហើយ ក្នុងនោះ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ក៏បានសហការជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ បញ្ជូនពួកគាត់ទៅទទួលការព្យាបាលពីក្រុមគ្រូពេទ្យជំនាញរួចរាល់ផងដែរ
- ក្នុងពេលចាប់ផ្តើមដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ នៅ**ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១** ខាងមុខនេះ លោកគ្រូ-អ្នកគ្រូ បុគ្គលិកអប់រំ និងសិស្សានុសិស្សទាំងអស់ ត្រូវបង្ហាញប័ណ្ណចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ មុនពេលចូលក្នុងគ្រឹះស្ថានសិក្សា។ ចំពោះលោកគ្រូ-អ្នកគ្រូ និងបុគ្គលិកអប់រំ ដែលមានអាយុលើសពី ៥០ ឆ្នាំឡើង ឬ មិនបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដោយសារបញ្ហាសុខភាព ក៏ដូចជាសិស្សានុសិស្សដែលមានជំងឺប្រចាំកាយមិនអាចចាក់វ៉ាក់សាំងបាន ត្រូវបន្តការបង្រៀន និងការរៀនតាមប្រព័ន្ធអនឡាញ។

**ជារួម** គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន សម្រាប់កម្រិតអនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ បានត្រៀមលក្ខណៈសម្បត្តិសមស្របក្នុងការបើកដំណើរឡើងវិញ ស្របតាមគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) របស់ក្រសួងអប់រំ យុវជន និងកីឡា និងការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ ពោលគឺអាចបើកដំណើរការចាប់ពីកាលបរិច្ឆេទដែលបានកំណត់តទៅ។ ដូច្នេះ សូមគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន លោកគ្រូ-អ្នកគ្រូ បុគ្គលិកអប់រំ មាតាបិតា-អាណាព្យាបាល សិស្សានុសិស្ស និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងជំរុញការបើកដំណើរការឡើងវិញនូវគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន នៅរាជធានីភ្នំពេញ ឱ្យទទួលបានលទ្ធផលល្អប្រកបដោយទំនុកចិត្តខ្ពស់។

ថ្ងៃអង្គារ ៨កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១

រដ្ឋបាលរាជធានីភ្នំពេញ



៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh